វិទ្យាស្ថានសភាកម្ពុជា
PARLIAMENTARY INSTITUTE OF CAMBODIA
STRENGTHENING PARLIAMENTARY CAPACITY

# ព្រឹត្តប័ត្រព័ត៌មានសង្ខេប

**សប្តាហ៍ដែលបញ្ចប់**
**ថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១៩**

ចំណុចសំខាន់ៗ អំពីព័ត៌មានសេដ្ឋកិច្ច និងការអភិវឌ្ឍសារពើពន្ធនៅក្នុងបណ្តាប្រទេសជាសមាជិកអាស៊ាន និងនៅប្រទេសផ្សេងៗទៀត នៅក្នុងសប្តាហ៍នេះគឺ៖

- កម្ពុជាគួរពិចារណាទាញយកអគ្គិសនីពីថាមពលព្រះអាទិត្យជំនួសថាមពលវារីអគ្គិសនី ដើម្បីអោយការឆ្លើយតប ទៅនឹងកង្វះខាតអគ្គិសនីកាន់តែឆាប់រហ័ស
- អតិរេកនៃតុល្យភាពទូទាត់របស់កោះតៃវ៉ាន់មានកម្រិតថយនៅក្នុងត្រីមាសទី១ ឆ្នាំ២០១៩
- ប្រធានធនាគារកណ្តាលអាមេរិកនិយាយថាហានិភ័យបំណុលឯកជនគឺមានកម្រិត"មធ្យម"

*ព្រឹត្តប័ត្រសង្ខេបព័ត៌មាននេះ គឺជាព្រឹត្តិប័ត្រប្រចាំសប្តាហ៍ដែលរៀបចំឡើងដើម្បីតាមដានព័ត៌មានអំពីការអភិវឌ្ឍសេដ្ឋកិច្ច និងសារពើពន្ធថ្មីៗនៅក្នុងប្រទេសកម្ពុជា និងដៃគូពាណិជ្ជកម្មនានា។ ឯកសារនេះត្រូវបានធ្វើឡើងដោយក្រុមការងារបណ្តុះបណ្តាលសមត្ថភាពការវិភាគសារពើពន្ធរបស់វិទ្យាស្ថានសភាកម្ពុជា ក្នុងគោលបំណងពង្រឹងជំនាញនៃការធ្វើឯកសារ និងការស្រាវជ្រាវរបស់ខ្លួន។ ការងារនេះត្រូវបានព្យាយាមធ្វើឡើងដើម្បីធានាថាការវិភាគ និងអត្ថន័យ ដែលបានផ្តល់នៅក្នុងឯកសារនេះមានគុណភាពខ្ពស់។ ទោះជាយ៉ាងណាក៏ដោយ សូមអ្នកអានចាត់ទុកឯកសារនេះជាផ្នែកមួយនៃលំហាត់អនុវត្តនៅក្នុងកំឡុងពេលនៃការបណ្តុះបណ្តាល។ យើងមិនអាចធានាថាឯកសារនេះល្អឥតខ្ចោះនោះទេ។*

## ព័ត៌មាន និងទិន្នន័យអំពីប្រទេសកម្ពុជា

### កម្ពុជាគួរពិចារណាទាញយកអគ្គិសនីពីថាមពលព្រះអាទិត្យជំនួសថាមពលវារីអគ្គិសនី ដើម្បីអោយការឆ្លើយតប ទៅនឹងកង្វះខាតអគ្គិសនីកាន់តែឆាប់រហ័ស

សមាគមថាមពលសូឡានៅកម្ពុជាបានលើកឡើងថា កម្ពុជា គួរតែសម្លឹងមើលការបង្កើនថាមពលពីពន្លឺព្រះអាទិត្យ មុននឹងពង្រីកមធ្យោបាយផលិតថាមពលវារីអគ្គិសនី ខណៈប្រទេសកម្ពុជាកំពុងប្រឈមនឹងកង្វះខាតថាមពលអគ្គិសនីជាញឹកញាប់។

ប្រធានសមាគមលោក សំ សុគន្ធ បាននិយាយថា ការរៀបចំតម្លើងថាមពលពន្លឺព្រះអាទិត្យគឺត្រូវការពេលវេលាតិចជាងការសាងសង់ទំនប់វារីអគ្គីសនី។ ទីតាំងផលិតថាមពលពីពន្លឺព្រះអាទិត្យចំនួនប្រាំ ដែលមានកំលាំងផ្ទុក ៦០មេហ្គាវ៉ាត់ អាចចំណាយពេលសាងសង់ត្រឹមរយៈពេល ៧ខែ ខណៈដែលការសាងសង់ទំនប់វារីអគ្គីសនីអាចត្រូវចំណាយពេលដល់ទៅ៥ឆ្នាំ។ លោក សំ សុគន្ធ បានបន្ថែមទៀតថា ទោះបីជាការផលិតថាមពលពីពន្លឺព្រះអាទិត្យ មានតំលៃថ្លៃ និងត្រូវការដីធំ ប៉ុន្តែផលប្រយោជន៍ដែលទទួលបានក្រោយពីការវិនិយោគគឺមានកម្រិតខ្ពស់។ កម្ពុជាបាននាំចូលថាមពលពីប្រទេសជិតខាងរួមមាន៖ វៀតណាម ឡាវ និងថៃ ប្រមាណ ១៥% នៃតម្រូវការប្រើប្រាស់សរុប ដែលនឹងកើនដល់២១% នៅចុងឆ្នាំ២០១៩ ដោយសារតម្រូវការកើនឡើង។

ទីតាំងផលិតថាមពលពីពន្លឺព្រះអាទិត្យ ដែលមានតំលៃ ១២,៥ លានដុល្លារ ជាមួយនឹង សមត្ថភាពផលិត១០មេហ្គាវ៉ាត់ថ្មីៗនេះគឺបានបញ្ចប់ការសាងសង់រួចរាល់ហើយនៅខេត្តស្វាយរៀង។ រោងចក្រថ្មីពីរដែលមានកំលាំងផលិត ៦០មេហ្គាវ៉ាត់ ត្រូវបានអនុញ្ញាតនៅក្នុងខេត្តពោធិសាត់ និងកំពង់ឆ្នាំង

ហើយរោងចក្រនៅខេត្តកំពង់ស្ពឺដែលមានកំលាំងផលិត៦០ មេហ្គាវ៉ាត់ កំពុងតែពង្រីក២០មេហ្គាវ៉ាត់បន្ថែមទៀតផងដែរ។

### តារាងប្រចាំសប្តាហ៍៖ ផលិតផលនាំចេញចម្បងរបស់កម្ពុជា និង អត្រាពន្ធរបស់សហភាពអឺរ៉ុប

ទំនិញនាំចេញសំខាន់ៗរបស់កម្ពុជាទៅកាន់សហភាពអឺរ៉ុប រួមមានសំលៀកបំពាក់ ស្បែកជើង កង់ និងអង្ករ។ យោងតាមតួលេខដែលបានប៉ាន់ស្មានសម្រាប់រយៈពេល១១ខែដំបូង នៃឆ្នាំ ២០១៨ តម្លៃនៃការនាំចេញផលិតផលទាំងនេះមានចំនួន ៥,៤៣៦ លានដុល្លារ ក្នុងនោះសំលៀកបំពាក់មានចំនួន ៧៧,៤% ស្បែកជើងមានចំនួន១៣,៤% កង់មានចំនួន ៦,១% និងអង្ករមានចំនួន ៣,១%។ ស្ថិតក្រោមតារាងពន្ធនាំចូលរបស់សហភាពអឺរ៉ុប ផលិតផលសម្លៀកបំពាក់ត្រូវជាប់ពន្ធនាំចូលក្នុងអត្រា ១២% ស្បែកជើង ១៦% និងកង់ ១០%។ នៅពេលថ្មីៗនេះ សហភាពអឺរ៉ុបបានដាក់ពន្ធគយថ្មីលើអង្ករកម្ពុជាដែលមានអត្រា ២៦,២% ។

| ផលិតផលនាំចេញ | តម្លៃ (គិតជាលានដុល្លារ) | ភាគរយ | អត្រាពន្ធសហភាពអឺរ៉ុប |
|---|---|---|---|
| ស្បែកជើង | ៤,២០៦.៣ | ៧៧.៣៧% | ១២.00% |
| សម្លៀកបំពាក់ | ៧២៩.២ | ១៣.៤១% | ១៦.00% |
| កង់ | ៣៣១.៦ | ៦.១0% | ១0.00% |
| អង្ករ | ១៦៩.៦ | ៣.១២% | ២៦.២0% |

ប្រភព៖ បច្ចុប្បន្នភាពសេដ្ឋកិច្ចកម្ពុជា ខែឧសភាឆ្នាំ ២០១៩

## ព័ត៌មាន និងទិន្នន័យរបស់បណ្តាប្រទេសនៅក្នុងអាស៊ាន និងដៃគូពាណិជ្ជកម្មផ្សេងទៀត

### អតិរេកនៃតុល្យភាពទូទាត់របស់កោះតៃវ៉ាន់មានកម្រិតថយនៅក្នុងត្រីមាសទី១ ឆ្នាំ២០១៩

យោងតាមសេចក្តីប្រកាសព័ត៌មានរបស់ធនាគាកណ្តាលនៃសាធារណរដ្ឋចិន(កោះតៃវ៉ាន់)បានអោយដឹងថា អតិរេកគណនីចរន្តរបស់តៃវ៉ាន់ នៅក្នុងត្រីមាសទី១ឆ្នាំ២០១៩ មានចំនួន១៧,១ ប៊ីលានដុល្លារអាមេរិក បើប្រៀបធៀបទៅនឹងរយៈពេលដូចគ្នាក្នុងឆ្នាំមុន គឺមានការធ្លាក់ចុះចំនួន ៥,១ ប៊ីលានដុល្លារអាមេរិក។

កត្តាសំខាន់ដែលនាំអោយមានការធ្លាក់ចុះនេះរួមមាន ការធ្លាក់ចុះនៃពាណិជ្ជកម្មទំនិញ ដែលមានទឹកប្រាក់ ១២,៤ ប៊ីលានដុល្លារ គឺថយពី ១៦,៤៣ ប៊ីលានដុល្លារកាលពីឆ្នាំមុន និងការធ្លាក់ចុះនៃអតិរេកប្រាក់ចំណូលបឋម (Primary income) ដល់ត្រឹម ៦,២ប៊ីលានដុល្លារ គឺថយពី ៧,៨ប៊ីលានដុល្លារ។ ឱនភាពនៃគណនីប្រាក់ចំណូលបន្ទាប់ (Secondary income) បានថយចុះដល់ 0,៨ប៊ីលានដុល្លារ និងសេវាកម្ម បានថយចុះដល់ 0,៧៦ ប៊ីលានដុល្លារ។

## សេដ្ឋកិច្ចពិភពលោក

### ប្រធានធនាគារកណ្តាលអាមេរិកនិយាយថា ហានិភ័យបំណុលឯកជនគឺនៅកម្រិត"មធ្យម"

យោងតាមលោក Jerome Powell ប្រធានធនាគារកណ្តាលអាមេរិកបានឱ្យដឹងថាបំណុលវិស័យឯកជនកំពុងកើនឡើង និងបង្កហានិភ័យមធ្យមដល់ប្រទេសដែលមានសេដ្ឋកិច្ចធំបំផុតរបស់ពិភពលោកមួយនេះ។

លោក Powell បានថ្លែងថា ទោះបីជាបំណុលឯកជនមិនទាន់គំរាមកំហែងដល់ស្ថិរភាពនៃប្រព័ន្ធហិរញ្ញវត្ថុក៏ដោយ ប៉ុន្តែវាអាចផ្តល់ផលប៉ះពាល់ដល់គ្រួសារ និងអាជីវកម្ម ប្រសិនបើអ្នកវិនិយោគមិនអាចសងបំណុល ឬប្រសិនបើសេដ្ឋកិច្ចកាន់តែយ៉ាប់យ៉ឺន។

ក្រុមសេដ្ឋវិទូបានព្រមានថា បន្ទាប់ពីរយៈពេលជាច្រើនឆ្នាំនៃការកើនឡើងនៃសេដ្ឋកិច្ច និងអត្រាការប្រាក់ទាប ក្រុមហ៊ុនអាមេរិកមានកម្រិតបំណុលខ្ពស់ជាងប្រាក់ចំណេញ បើធៀបនឹងកាលពីមុន។ ប្រសិនបើអត្រាការប្រាក់កើនឡើង ឬសេដ្ឋកិច្ចថមថយល្បឿននោះ ក្រុមហ៊ុនប្រហែលជាមិនអាចបំពេញកាតព្វកិច្ចរបស់ពួកគេក្នុងការសងបំណុលបានទេ។ ទោះជា

យ៉ាងណាក៏ដោយ ក្រោយវិបត្តិហិរញ្ញវត្ថុ ធនាគារជាច្រើនបានចាត់វិធានការដោយប្រុងប្រយ័ត្នដើម្បីដោះស្រាយការខាតបង់ នេះបើយោងតាមលោក Powell។

របាយការណ៍ចុងក្រោយរបស់ធនាគារកណ្តាលស្តីពីស្ថិរភាពហិរញ្ញវត្ថុបានព្រមានស្រដៀងគ្នាថា ការកើនឡើងនៃហានិភ័យបានរក្សាតម្លៃភាគហ៊ុនធៀបនឹងប្រាក់ចំណេញដែលរំពឹងទុកលើសពីកម្រិតមធ្យម ក្នុងរយៈពេល៣០ឆ្នាំចុងក្រោយនេះ។ លើសពីនេះទៀត ថ្មីៗនេះមូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) ក៏បានព្រមានផងដែរថា កម្រិតបំណុលខ្ពស់បង្កហានិភ័យដល់សេដ្ឋកិច្ចអន្តរជាតិ។

## ព័ត៌មានសម្រាប់សប្តាហ៍បន្ទាប់

ទិន្នន័យសម្រាប់សប្តាហ៍ខាងមុខនេះ រួមមាន៖ ផលិតកម្មឧស្សាហកម្មនៅប្រទេសចិន ប្រទេសថៃ និងកូរ៉េខាងត្បូង។ ធនាគារកណ្តាលកូរ៉េខាងត្បូងក៏នឹងប្រកាសពីការសម្រេចចិត្តអត្រាការប្រាក់។

ខាងក្រោមគឺជាប្រតិទិនពេញលេញនៃការចេញនូវទិន្នន័យ និងការអភិវឌ្ឍ ដែលក្រុម FACT នឹងបន្តតាមដាននៅសប្តាហ៍ក្រោយ៖

<u>ថ្ងៃចន្ទ ទី២៧ ឧសភា ២០១៩</u>

- ផលិតកម្មឧស្សាហកម្មរបស់ចិន សម្រាប់ខែមេសា
- តុល្យភាពពាណិជ្ជកម្មហុងកុង សម្រាប់ខែមេសា

<u>ថ្ងៃអង្គារ ទី២៨ ឧសភា ២០១៩</u>

- ភាពជឿទុកចិត្តរបស់អ្នកប្រើប្រាស់របស់កូរ៉េខាងត្បូង សម្រាប់ខែឧសភា
- ភាពជឿទុកចិត្តរបស់អ្នកប្រើប្រាស់របស់តៃវ៉ាន់ សម្រាប់ខែឧសភា
- ផលិតកម្មឧស្សាហកម្មរបស់ថៃ សម្រាប់ខែមេសា
- សន្ទស្សន៍តម្លៃផ្ទះនៅអាមេរិក សម្រាប់ខែមីនា

<u>ថ្ងៃពុធ ទី២៩ ឧសភា ២០១៩</u>

- ទំនុកចិត្តទៅលើអាជីកម្មរបស់កូរ៉េខាងត្បូង សម្រាប់ខែឧសភា
- តុល្យភាពពាណិជ្ជកម្មវៀតណាម សម្រាប់ខែឧសភា
- អត្រាអតិផរណារបស់វៀតណាម សម្រាប់ខែឧសភា
- តម្លៃក្នុងការនាំចេញ/ចូលរបស់សឹង្ហបុរី សម្រាប់ខែមេសា

<u>ថ្ងៃព្រហស្បតិ៍ ទី៣០ ឧសភា ២០១៩</u>

- សន្ទស្សន៍តម្លៃអ្នកផលិតរបស់ម៉ាឡេស៊ី សម្រាប់ខែមេសា
- សន្ទស្សន៍តម្លៃការលក់រាយរបស់ហ្វីលីពីនសម្រាប់ខែមេសា
- អត្រានិកម្មភាពរបស់ថៃ សម្រាប់ខែមេសា

<u>ថ្ងៃសុក្រ ទី៣១ ឧសភា ២០១៩</u>

- ផលិតកម្មឧស្សាហកម្មរបស់កូរ៉េខាងត្បូង សម្រាប់ខែមេសា
- ការសម្រេចទៅលើអត្រាការប្រាក់របស់កូរ៉េខាងត្បូង
- សន្ទស្សន៍តម្លៃអ្នកប្រើប្រាស់(CPI)របស់ជប៉ុន សម្រាប់ខែឧសភា
- ផលិតកម្មឧស្សាហកម្មរបស់ជប៉ុន សម្រាប់ខែមេសា
- អត្រានិកម្មភាពរបស់ជប៉ុនសម្រាប់ខែមេសា
- កម្ចីរបស់ធនាគារសឹង្ហបុរី សម្រាប់ខែមេសា
- ការលក់រាយរបស់ប្រទេសថៃ សម្រាប់ខែឧសភា
- ការលក់រាយរបស់ហុងកុង សម្រាប់ខែឧសភា